# ការនិយាយប្រាប់រឿងរបស់ជនជាតិខ្មែរ

ពី ស៊ិល្លមិន ម៉ាក

បកប្រែដោយអ្នកនាង យី មកភា

តើខ្មែរជានរណា? ខ្មែរមានន័យដូម្តេច? ខ្ញុំក៏មិនស្គាល់ច្បាស់ដែរថាខ្មែរជានរណាឬក៏មានយ៉ាងម៉េចដែរ។ ទោះបីជាខ្ញុំជា Caucasian ដែលមានស្បែកស ក៏ខ្ញុំកំពុងតែស្វែងរកចំលើយចំពោះសំនួរដែលថា តើខ្មែរជានរណា។ មិនប៉ុន្មាននាក់ទេនៃមនុស្សលើលោកនេះដែលស្គាល់ខ្មែរ។ យើងមិនគួរទុកអោយមនុស្សលើលោកនេះ មិនដឹង មិនស្គាល់ខ្មែរ ហើយមិនដឹងថាជនជាតិខ្មែរបានចូលរួមចំណែកយ៉ាងសំខាន់ចំពោះការរីកចំរើននៃអារ្យធម៌របស់ពិភពលោកនេះទេ។

តើនរណានឹងនិទានពីប្រវត្តិរបស់ខ្មែរ?

ខ្ញុំនឹងសុំអោយខ្មែរគ្រប់គ្នានៅទីនេះ ថ្ងៃនេះ ថាអ្នកនឹង ជួយខ្ញុំនិទានពីប្រវត្តិរបស់ខ្មែរដែរឬទេ? ដើម្បីនិយាយពីដំណើររឿងនេះ យើងគួរចាប់ផ្តើមតំបូងដោយពិនិត្យលើប្រវត្តិសាស្ត្ររបស់ខ្មែរ ការជឿជាក់លើអនុភាពដែលគ្មានព្រំដែលនៃបច្ចុប្បន្នកាល ហើយនិងបើកចំហរទទួលយកនូវលទ្ធភាពដែលអាចកើតមាននាពេលអនាគត ។ ការចាប់ផ្តើមដោយដឹងថាខ្លួនអ្នកជាសមាសធាតុនៃ អតីតកាល បច្ចុប្បន្នកាល និងជាសេចក្តីសង្ឃឹមក្នុងការរក្សានូវ វប្បធម៌ តំលៃ និងប្រពៃណីរបស់ខ្មែរ ទៅអនាគត ។

ខ្ញុំនឹងចាប់ផ្តើមបូងដោយនិយាយពីប្រវត្តិសាស្ត្ររបស់ខ្មែរ បន្ទាប់មកគឺបច្ចុប្បន្នកាលនឹងជាចុងបញ្ចាប់ គឺអនាគតកាលរបស់ខ្មែរ ។

ប្រវត្តិសាស្ត្រ

ជនបរទេសខ្លះ ស្គាល់ខ្មែរតាមរយៈ វាលពិឃាត " Killing Fields "
ទោះបីជារបបនេះជារយៈកាលសោនាដ្ឋកម្ម នៃប្រវត្តិសាស្ត្រខ្មែរក៏ដោយ
ក៏ប៉ុន្តែមានអ្វីៗជាច្រើនក្រៅពីនេះ ដែលគួរអោយចាប់អារម្មណ៍ នឹង
ចង់ដឹងជាជាងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងកំឡុងឆ្នាំ 1975 ~ 1979 ។
ប្រវត្តិសាស្ត្រខ្មែរចាប់ផ្តើមជាង ២០០០ ឆ្នាំមុន ជាមួយនឹងការ
ក៏កើតឡើងនូវអាណាចក្រ ហ្វូណាន។ អាណាចក្រនេះបានបញ្ចប់នា
នាសតវត្ស ទី៧ ហើយជំនួសដោយអាណាចក្រ " ចេនឡា " ។
អាណាចក្រ ចេនឡាបែងចែកជាពីរផ្នែកគឺចេនឡាដីគោកដែលរួមមាន
ហ្វូណាន ប្រទេសឡាវ និងភាគខាងជើង នៃប្រទេសកម្ពុជាបច្ចុប្បន្នរីឯ
មួយផ្នែកទៀត គឺចេនឡាដីទឹកដែលរួមមាន
ផ្នែកខាងក្រោមទន្លេមេគង្គ ។ ផ្អែកទៅលើកាកត់ត្រារបស់លោក ជីវតា
ក្វាន់ ដែលរាជទូតរបស់ប្រទេសចិន បានសរសេរថា អានាចក្រនេះ
បានបង្កើតឡើងដោយព្រាហ្មជនជាតិឥណ្ឌាម្នាក់ឈ្មោះ កៅណ្ឌិន ឬ
ព្រះបាទហ៊ុនទៀង ដែលបានរៀបអភិសេធនិងព្រះនាងសោម៉ា ដែលជា
បុត្រីរបស់ស្តេចនាគ។ ការកកើតនេះប្រហែលជាប្រមាណទស្សវត្ត
ប៉ុណ្ណោះ បន្ទាប់ពីមរណៈភាពរបស់ព្រះយេស៊ូគ្រីស្ត វាក់ដំណាលគ្នានឹង
គម្ពីព្រះត្រៃបីតក ដែលត្រូវបានគេកត់ត្រាជាភាសាបាលី ហើយក៏
ដំណាលពាលនឹងភាពរុងរឿងដ៏កំពូលរបស់ចក្រភព រ៉ូម៉ាំង ។

នាឆ្នាំ 800 បន្ទាប់គ្រឹស្តកករាជ អាណាចក្រចេនឡាបានគ្រប់គ្រងដោយ
បុត្រារបស់អតីតស្តេចខ្មែរដែលជំលាសទៅប្រទេសជ្វានិងបានបង្រួប
បង្រួម ហើយបង្កើតនូវអាណាចក្រខ្មែរតំបូងបង្អស់គឺព្រះបាទជ័យវ័ន្ម
ទី II ។ ព្រះបាទសូរិយាវរ័ន្ម ទី VII បានកសាងអង្គរវត្ត ផ្តើមពីឆ្នាំ 1181
ដល់ឆ្នាំ 1220 ដែលជាប្រាសាទ សាសនាធំបំផុតលើលោក។ ចំនួនថ្ម
ដែលគេបានយកមកសាងអង្គរវត្ត គឺ

ស្មើទៅនឹងចំនួនថ្មដែលគេប្រើប្រាស់ក្នុងការសាងសង់ អច្ឆរិយ្យ ពី ពីរ៉ាមីត នៅ ឆេអប ប្រទេសអេស៊ីប។

នាចំនុចរីកចំរើនដ៏ជំពូលនាសម័យអង្គរ ប្រាសាទអង្គរធំ នកសាងដោយ ព្រះបាទជ័យវរន្ម័ ទី VII ដែលរាប់បញ្ចូលទាំង វាំងតំរីនិងលានស្តេច គំលង់ ដែលមានចំនួនប្រជាជនជិតមួយលាននាក់ ហើយមានទំហំ ៩ គីឡូម៉ែត្រក្រឡា ដែលទំហំបែក អឺរុប ណាមួយ មិនអាចប្រៀបធៀបបាន នាពេលនេះ ។

នាចុងសតវត្ស ទី 12 ព្រះបាទជ័យវរន្ម័ ទី VII ក៏បានស្ថាបនាថ្នល់ជាតិ មួយចំនួនដែលមានសមាមាត្របន្តិចបន្តួចទៅនឹងផែនដីយើង ។ គេអាច មើលឃើញផ្លូវទាំងនោះតាមរយះផ្កាយរនប ដែលមានប្រវែងជាង 220 គីឡូម៉ែត្រពីទិសខាងជើងទៅទិសខាងត្បូងរហូតដល់នឹង ភីម៉ៃ ប្រទេស ថៃបច្ចុប្បន្ន ។ រំលឹកទៀងវិញនូវប្រវត្តិសាស្ត្រដ៏រុងរឿងរបស់ខ្មែរធ្វើអោយ យើងមានអំណួតទៅនឹងសមិទ្ធិផលដែលប្រជាជនខ្មែរបានរួមចំណែក ចំពោះវប្បធម៌ សិល្បះ ភាសា វិទ្យាសាស្ត្រ និង អារ្យធម៌ ។ ការមើល ត្រលប់ទៅរកអតីតកាលដែលល្អ គឺ ជាអ្វីដែលយើងអាចធ្វើទៅបាននា ពេលបច្ចុប្បន្ននេះ ។

<u>បច្ចុប្បន្ន</u>

ភាពអស្ចារ្យដ៏ពិតប្រាកដរបស់មនុស្ស មិនបិតតែលើអតីតកាលនៅពេល ដែលបុព្វបុរសបានសាងសង់ប្រសាទអង្គរនោះទេ នៅពេលដែល បុព្វបុរសបានសាងសង់ប្រាសាទ គឺរយះពេលនោះជាបច្ចុប្បន្នកាលរបស់ ពួកគាត់ ។ អ្នកកំពុងឈរនៅទីនេះ ពេលនេះ មិនមែនជាថ្ងៃម្សិលមិញ ឬអនាគតឡើយ អ្នកមានតែឥឡូវនេះ ដើម្បីគិត និងឥឡូវនេះដើម្បីធ្វើ អ្នកមានកំលាំងអនុភាពដែលគ្មានថ្ងៃហួតហែង សំនួរគឺបិតនៅត្រង់ថា